**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ : ០០១/១០ កប/ស.ជ.ណ

**សេចក្តីជូនដំណឹង**

**ស្តីពីការដាក់ពាក្យស្នើសុំមូលនិធិជាតិបណ្តុះបណ្តាល**

**ដើម្បីកាត់បន្ថយភាពក្រីក្រ**

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកិត្តិយសសូមជូនដំណឹងដល់អង្គភាពបណ្តុះបណ្តាល បច្ចេកទេស និងវិជ្ជាជីវៈ ទាំងផ្នែកសាធារណៈ ឯកជន អង្គការក្រៅរដ្ឋាភិបាល ឱ្យបានជ្រាបថា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានកម្មវិធីមួយឈ្មោះថា មូលនិធិជាតិបណ្តុះបណ្តាលដើម្បីកាត់បន្ថយភាពក្រីក្រ ។ កម្មវិធីនេះមានមូលនិធិសម្រាប់ផ្តល់ជូនដល់អង្គភាពបណ្តុះបណ្តាលដែលស្របច្បាប់ មានបទពិសោធន៍ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់យកទៅបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈជូនដល់ក្រុមគោលដៅ ដូចជា ជនទីទ័លក្រ ស្ត្រីមេម៉ាយ ក្មេងកំព្រា សិស្សបោះបង់ចោលការសិក្សា ជនពិការ ។ល។

នៅក្នុងឆ្នាំ២០១០ នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានគម្រោងផ្តល់ឱ្យអង្គភាពបណ្តុះបណ្តាលនូវមូលនិធិសម្រាប់ការបណ្តុះបណ្តាលជំហានទីមួយ ដោយធ្វើការពង្រាយគ្រប់រាជធានី-ខេត្តទូទាំងប្រទេស ។

អាស្រ័យហេតុនេះ អង្គភាពបណ្តុះបណ្តាលដែលសមស្រប និងឆ្លើយតបទៅតាមគោលការណ៍លក្ខណៈវិនិច្ឆ័យដែលបានកំណត់ អាចអញ្ជើញមកទាក់ទង និងដាក់ពាក្យស្នើសុំនៅការិយាល័យមូលនិធិជាតិបណ្តុះបណ្តាលនៃនាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានអាស័យដ្ឋានអគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី ចាប់ពីថ្ងៃជូនដំណឹងរហូតដល់ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ រៀងរាល់ថ្ងៃធ្វើការ ចាប់ពីថ្ងៃច័ន្ទ ដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៧:៣០ នាទី ដល់ម៉ោង ១១:៣០ នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០ នាទី ដល់ម៉ោង ១៧:៣០ នាទី ។

រាជធានីភ្នំពេញ,ថ្ងៃទី ២៦ ខែមករា ឆ្នាំ២០១០

**រដ្ឋមន្ត្រី**

**វង សូត**

<u>ចម្លងជូន</u>

- -ខុទ្ទកាល័យលោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រីប្រចាំការ
- -ក្រសួង-ស្ថាប័ន ដែលពាក់ព័ន្ធ
- -មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី-ខេត្ត
- -គ្រឹះស្ថានសិក្សាក្រោមឱវាទក្រសួង
- -អង្គការនានា "*ដើម្បីជួយផ្សព្វផ្សាយ*"
- -កាលប្បវត្តិ-ឯកសារ
- -<u>ទូរស័ព្ទទំនាក់ទំនង</u> : ០១៧ ៥១៨ ៧៥៨